# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាខួប២០ឆ្នាំរបស់លោកនៅប្រទេសកម្ពុជា
# គិរីរម្យ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៩
# សាងសង់ផ្ទះនៃសេចក្ដីស្រឡាញ់

**អត្ថបទទី១៖ អេសាយ ៦,១-២ក.៣-៨**

បន្ទាប់មក ខ្ញុំឮព្រះសូរសៀងរបស់ព្រះអម្ចាស់ដែលមានព្រះបន្ទូលថា៖ «តើយើងនឹងចាត់អ្នកណាឲ្យទៅ តើនរណានឹងនាំពាក្យរបស់យើង?»។ ខ្ញុំទូលឆ្លើយថា៖ «ទូលបង្គំនៅទីនេះស្រាប់ហើយ! សូមព្រះអង្គចាត់ទូលបង្គំចុះ!»។ អស ៦,៨

**អត្ថបទទី២៖ កូរិនថូសទី១ ១៥,១-១១**

ប្រសិនបើបងប្អូនមិនឃ្លាតចាកពីដំណឹងល្អ ដែលខ្ញុំបានប្រកាសប្រាប់បងប្អូនទេនោះ បងប្អូននឹងទទួលការសង្គ្រោះ តាមរយៈដំណឹងល្អនេះដែរ។ បើឃ្លាតចាក ជំនឿរបស់បងប្អូនមុខតែឥតប្រយោជន៍។ ១ករ ១១,២

**ដំណឹងល្អ៖ លូកា ៥,១-១១**

ព្រះយេស៊ូមានព្រះបន្ទូលទៅលោកស៊ីម៉ូនថា៖ «កុំខ្លាចអី! ពីពេលនេះទៅមុខ អ្នកនឹងនេសាទមនុស្សវិញ»។ លក ៥,១០

បងប្អូនជាទីស្រឡាញ់!

មូលហេតុអ្វីបានយើងជួបជុំគ្នាក្នុងព្រៃដូច្នេះ? អម្បាញមិញព្រះជាម្ចាស់បានជ្រើសរើសអត្ថបទដើម្បីឲ្យយើងស្ដាប់នៅថ្ងៃនេះ អត្ថបទទី២សន្តប៉ូលបាននិយាយថា "**ក៏ប៉ុន្តែមិនមែនខ្ញុំដែលធ្វើការ គឺព្រះហឫទ័យប្រោសប្រណីរបស់ព្រះជាម្ចាស់ដែលស្ថិតនៅជាមួយខ្ញុំទេតើ ដែលបានសម្រេចគ្រប់កិច្ចការ**"។ ពេលខ្ញុំនឹកឃើញដំណើរជីវិតប៉ុន្មែ២០ឆ្នាំខ្ញុំជាបូជាចារ្យ និងបីថ្ងៃមុនជាខួប៥០ឆ្នាំនៃអគ្គសញ្ញាអាពាហ៍ពិពាហ៍របស់ឪពុកម្ដាយខ្ញុំ គឺនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៦៩។ មួយឆ្នាំក្រោយមក មានខ្ញុំជាកូនង៉ែតម្នាក់ ដែលមានទម្ងន់៣គីឡូ២៥០ក្រាម ដែលបានកើតនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៧០។ បីខែក្រោយមក ខ្ញុំបានទទួលអគ្គសញ្ញាជ្រមុជទឹក ព្រះជាម្ចាស់បានណែនាំឲ្យខ្ញុំកើតនៅក្នុងគ្រួសារគ្រីស្តបរិស័ទ និងខ្ញុំបានទទួលអគ្គសញ្ញាជ្រមុជទឹកតាមប្រពៃណី។ នៅពេលចាប់ផ្ដើមធំហើយ ឪពុកម្ដាយធ្វើតាមប្រពៃណីដូចនាងម៉ារីនិងលោកយ៉ូសែប ណែនាំឲ្យកូនចូលវិហាររាល់ថ្ងៃអាទិត្យ ដូចគ្រួសារមួយចំនួននៅទីនេះដែរ។ រហូតដល់ខ្ញុំអាយុ៨ឆ្នាំ៩ឆ្នាំ ខ្ញុំចូលចិត្តពាក់អាវសនិងថ្វាយអភិបូជា ជូនកាលខ្ញុំហៅតាយាយឪពុកម្ដាយដើម្បីចូលរួមអភិបូជាដែលខ្ញុំថ្វាយ។ ពេលប្អូនស្រីខ្ញុំបានទទួលតុក្កតាថ្មីមួយ រាល់ដងយើងចូលបន្ទប់ទឹកពីរនាក់នឹងខ្ញុំធ្វើពិធីជ្រមុជទឹកឲ្យតុក្កតាហ្នឹង ដោយសារខ្ញុំបានឃើញនៅព្រះវិហារលោកបូជាចារ្យធ្វើអគ្គសញ្ញាជ្រមុជទឹក។

ពេលខ្ញុំឡើងធំបន្តិច ចេះតែគិតខ្ញុំចង់ធ្វើជាបូជាចារ្យដូចលោកដែលខ្ញុំឃើញជារៀងរាល់អាទិត្យ ប៉ុន្តែខ្ញុំអត់ដែលទៅណាទេមួយជីវិត ខ្ញុំនៅក្នុងផ្ទះជាមួយឪពុកម្តាយ ដើរលេងក៏មិនចេះ មិត្តភក្តិមិនសូវមានទេ ខ្ញុំដើរលេងតែម្តងគត់នៅក្នុងថ្ងៃខួបកំណើតអាយុ១៨ឆ្នាំ ខ្ញុំរៀបចំកម្មវិធីដើរលេងមួយថ្ងៃ។ ពេលខ្ញុំចូលទេវវិទ្យាល័យ ណែនាំឲ្យលោកតាខ្ញុំអន់ចិត្តណាស់ ព្រោះគាត់ចង់ឲ្យខ្ញុំធ្វើជាគ្រូពេទ្យ។ ខ្ញុំឥតស្គាល់ពិភពលោក ឥតស្គាល់ទ្វីបអាស៊ី ខ្ញុំស្គាល់តែភូមិខ្ញុំ អត់ដែលមានគំនិតទៅឆ្ងាយទេ ប៉ុន្តែព្រះជាម្ចាស់គិតផ្សេងពីយើង នៅពេលខ្ញុំនៅទេវៈមួយឆ្នាំ ខ្ញុំបានឃើញមានកម្មវិធីមួយទៅស្គាល់ជីវិតម្យ៉ាងសាសនាទូត ប្រកាសដំណឹងល្អនៅប្រទេសថៃ ខ្ញុំក៏បានចុះឈ្មោះនៅខែសីហា ឆ្នាំ១៩៩០ ខ្ញុំបាននៅប្រទេសថៃមួយខែ។ លើកទី១ដែលខ្ញុំជិះយន្តហោះ លើកទី១ដែលខ្ញុំស្គាល់ប្រទេសដែលក្តៅមែនទែន។ រយៈពេល១ខែនោះ ខ្ញុំចេះតែវិលមុខបែកញើស ញ៉ាំក៏មិនចូល ខ្ញុំស្រក់១០គីឡូក្រាម។ គេឲ្យខ្ញុំដេកក្នុងវាលស្រែពេញមួយយប់ នៅក្នុងឃ្លាំងជាប់ជាមួយម៉ាស៊ីនភ្លើង ចាប់ពីពេលនោះមកពេលខ្ញុំលឺសម្លេងម៉ាស៊ីនភ្លើងខ្ញុំចង់ផ្ទុះ ខ្ញុំភ័យ វានៅក្នុងខ្លួនអស់ហើយ។ នៅថៃថ្ងៃចុងក្រោយ ខ្ញុំបានទៅលេងមាត់សមុទ្រនិងខ្ញុំបាត់ខ្សែកមានមេដៃដែលខ្ញុំបានទទួលសម្រាប់អគ្គសញ្ញាជ្រមុជទឹករបស់ខ្ញុំ។ ដូច្នេះសព្វថ្ងៃនៅឆ្នេរសមុទ្រប្រទេសថៃ ខ្ញុំបានសាបព្រោះមេដៃនៃអគ្គសញ្ញាជ្រមុជទឹករបស់ខ្ញុំ។

ពេលនៅទេវៈ២ឆ្នាំហើយ នៅសម័យនោះយើងត្រូវការធ្វើទាហ៊ានបម្រើប្រទេស១ឆ្នាំ តែខ្ញុំអត់ចង់ធ្វើទាហ៊ានទេ។ ដូច្នេះប្រសិនបើ អត់ចង់ធ្វើទាហ៊ានយើងអាចទៅប្រទេសផ្សេងបម្រើ២ឆ្នាំ ខ្ញុំបានចុះឈ្មោះទៅបម្រើនៅប្រទេសអាហ្វ្រិក ដើម្បីជួយអ្នកក្រីក្រ ដោយសារខ្ញុំអត់ដែលស្គាល់អ្នកក្រីក្រទាល់តែសោះ។ ប៉ុន្តែ អ្នកដែលជ្រើសរើសដើម្បីចាត់យើងឲ្យទៅប្រទេសផ្សេងៗ គាត់ឃើញខ្ញុំធ្លាប់ទៅប្រទេសថៃ ដូច្នេះគាត់អត់ឲ្យខ្ញុំទៅអាហ្វ្រិចទេ គឺឲ្យខ្ញុំទៅប្រទេសជប៉ុនដែលជាប្រទេសមានជាងគេនៅក្នុងពិភពលោក។ ព្រះជាម្ចាស់ជ្រើសរើសផ្សេងពីអ្វីដែលយើងគិត លោកដែលផ្ញើខ្ញុំទៅគាត់ថា អត់អីទេនៅទីនោះមានអ្នកមានមែន ប៉ុន្តែក៏មានអ្នកក្រីក្រតាមផ្លូវវិញ្ញាណតាមផ្លូវចិត្តដែរ។ នៅប្រទេសជប៉ុន អត់មានអ្នកស្វាគមន៍ ខ្ញុំពិបាកទាំងម្ហូបអាហារ ទាំងទំនាក់ទំនង ដោយសារទាក់ទងជាមួយជនជាតិជប៉ុនពិបាកណាស់។ ប៉ុន្តែក្រោយមកចាប់ចូលនៅក្នុងជីវិតនៃប្រទេសជប៉ុន នៅឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩៣ ខ្ញុំមានមិត្តភក្តិជនជាតិជប៉ុនម្នាក់នាំខ្ញុំទៅណាហ្កាសាគី ដែលមានគ្រីស្តបរិស័ទដែលបានរស់នៅ ក្នុងសម័យដែលគេបៀតបៀនសាសនាកាតូលិកនៅជប៉ុន។

នៅក្នុងឆ្នាំ១៨៦០ គឺ២៥០ឆ្នាំក្រោយមកគេរកឃើញគ្រីស្តបរិស័ទដែលរស់នៅក្នុងព្រៃដែលបន្តជំនឿអស់សមត្ថភាព។ នៅពេលនោះមានបូជាចារ្យម្នាក់ដែលមក និងពេលខ្ញុំទៅដល់

ព្រះវិហារគាត់ ឃើញស្នាដៃរបស់គាត់វាចូលនៅក្នុងចិត្តខ្ញុំ ហើយខ្ញុំថាខ្ញុំចង់ធ្វើដូចគាត់ ដែលគាត់បានប្រមូលគ្រីស្តបរិស័ទនៅក្នុងព្រៃឲ្យចូលព្រះវិហារវិញ។ នៅឆ្នាំ១៨៦០ ប្រទេសជប៉ុនក្រ ដូច្នេះលោកបូជាចារ្យនោះគាត់បើករោងចក្រត្បាញសូត្រនិងអំបោះ ក្រោយមកគាត់បានបង្កើតរោងចក្រធ្វើទឹកស៊ីអ៊ីវជប៉ុន និងគាត់បើករោងចក្រធ្វើមីជប៉ុនដែលល្បីដល់សព្វថ្ងៃ ជាមួយស្ត្រីៗក្រីក្រនៅជុំវិញព្រះវិហារគាត់ ក្រោយមកគាត់អភិវឌ្ឍកសិកម្ម គាត់រៀបចំក្រុមភ្លេង នេះទាំងអស់វាចូលក្នុងចិត្តខ្ញុំហើយខ្ញុំចង់ធ្វើដូចគាត់។

ពេលទៅប្រទេសបារាំងវិញ ខ្ញុំបានចូលក្រុមសាសនទូតដើម្បីទៅជាអ្នកប្រកាសដំណឹងល្អ ដោយគិតថាខ្ញុំទៅប្រទេសជប៉ុន ឬប្រទេសចិនជាដាច់ខាត។ ថ្ងៃតែងតាំងខ្ញុំជាឧបដ្ឋាក ប្រធានក្រុមសាសនទូតខ្ញុំប្រកាសថា "**យើងបានជ្រើសរើសលោក អូលីវីយេ ដើម្បីទៅជាសាសនទូតនៅប្រទេសកម្ពុជា**"។ ពេលនោះប្អូនប្រុសខ្ញុំបេនមានអាយុតែ៩ឆ្នាំ គាត់ថា "**ឲ្យគាត់ទៅប្រទេសសុទ្ធតែគ្រាប់មីន**" ដោយសារប្រទេសកម្ពុជានៅឆ្នាំ១៩៩៧ ល្បីនៅអឺរ៉ុបសុទ្ធតែមីន គ្រួសារខ្ញុំទាំងអស់គេភ័យគេអត់ចង់ឲ្យខ្ញុំទៅទេ។ មកដល់ប្រទេសកម្ពុជា ខ្ញុំចាប់ផ្តើមរស់នៅដោយរៀនភាសាខ្មែរ អរគុណព្រះជាម្ចាស់ដែលណែនាំឲ្យខ្ញុំទៅដល់ស្វាយស៊ីសុផុន និងចំណោម ដើម្បីស្គាល់ជីវិតខ្មែរ។ ខ្ញុំឆ្លងសតវត្សទី២០ដល់២១នៅចំណោម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៩ ចូលឆ្នាំ២០០០នៅទីនោះជាមួយឪពុកខ្ញុំដែលមកលេង។

ក្រោយមក ខ្ញុំមកភ្នំពេញវិញខ្ញុំចាប់ផ្តើមរស់នៅជាមួយនិស្សិតខ្លះៗ នៅឆ្នាំ១៩៩៩លោកតាប៉ុងសូ ឲ្យខ្ញុំស្គាល់គ្រួសារមួយដែលរស់នៅរ៉ារថភ្លើង មួយអាទិត្យ២ឬ៣ដងខ្ញុំទៅដេកនៅទីនោះដើម្បីរៀនភាសាខ្មែរស្គាល់ជីវិត និងម្តាយនៅក្នុងគ្រួសារនោះ គាត់បានឲ្យក្រមារមួយមកខ្ញុំ និងគាត់ថាឥឡូវនេះ អូលីវីយេ នៅក្នុងគ្រួសារយើងហើយ។ ក្រោយមកនៅឆ្នាំ២០០១ ខ្ញុំបានបង្កើតមណ្ឌលនិស្សិត JEJ ហើយខ្ញុំសង្ឃឹមថាលោកអភិបាល អេមីល នឹងឲ្យខ្ញុំធ្វើជាអ្នកទទួលខុសត្រូវមណ្ឌលនិស្សិតកាតូលិកនៅភ្នំពេញ ដល់ពេលវេលាទទួលតួនាទីពិតៗលោកអេមីលប្រាប់ថាដល់ពេលវេលាសម្រាប់ អូលីវីយេ ទៅប្រកាសដំណឹងល្អនៅកំពតនិងតាកែវជាមួយលោក លី។ ពេលចេញពីសំណាក់ធម៌បូជាចារ្យនៅកំពង់សោម ខ្ញុំបានជិះម៉ូតូធំទៅមើលកំពត ផ្លូវយ៉ាប់មែនទែនហើយមានភ្លៀងទៀត។ លោកអេមីលហាមខ្ញុំមិនឲ្យទៅមើលទេ ត្រូវការចាំលោក លីតែងតាំងជាបូជាចារ្យសិន។ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០០២ ខ្ញុំដួលម៉ូតូ ពេលនោះលោកគ្រូជៀងចាំទទួលខ្ញុំនៅមន្ទីរពេទ្យភ្នែកតាកែវ ជាមួយប្រធានមន្ទីរធម្មការនិងសាសនាខេត្តតាកែវ។ ព្រឹកឡើងជាមួយអាវក្រហមពោរពេញដោយឈាមផង ក្នុងខ្លួនមិនសូវស្រួលសោះ ទៅជាមួយលោកលី ដើម្បីជួលផ្ទះនៅកំពត។

ព្រះជាម្ចាស់ឲ្យខ្ញុំនៅទីនោះ ឆ្នាំដំបូងមានតែបីនាក់ គឺមានម៉ន លោកលី និងខ្ញុំ យើងអត់មានអ្វីធ្វើប៉ុន្មានទេ លោក លី ទៅជុំគិរី ខ្ញុំទៅចំការទៀង រាល់ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ។ ក្រោយមកព្រះជាម្ចាស់បានរៀបចំឲ្យជីវិតរស់នៅរបស់យើង ដូចអត្ថបទដែលយើងបានស្ដាប់ "**យើងមិនសម្រេចចិត្ត ប៉ុន្តែអ្វីដែលព្រះជាម្ចាស់បានជ្រើសរើស បានសម្រេចចិត្ត គឺបានកើតឡើងប្លែក**" ប្រសិនបើសម្រេចចិត្តខ្លួនឯង គម្រោងការយើងវាអត់ទៅមុខ។ ប៉ុន្តែប្រសិនបើយើងធ្វើអ្វីដែលយើងឃើញ និងព្រះជាម្ចាស់ណែនាំឲ្យយើងទៅមុខយើងអាចទៅមុខបាន។

ដូច្នេះ ខ្ញុំមានឱកាសជួបជាមួយបិតានៃព្រះសហគមន៍ គឺនៅចំការទៀងយើងមានលោកគ្រូ ជៀង នៅជុំគិរីយើងមានមីង អាន នៅគិរីវង់យើងមានលោកតា ចយ...។ ព្រះជាម្ចាស់ឲ្យខ្ញុំជួបជាមួយលោកគ្រូ ជៀង លោកគ្រូជៀងអត់ជួបខ្ញុំអត់ទៅមុខ ហើយបើខ្ញុំអត់ជួបលោកគ្រូជៀងក៏អត់ទៅមុខ។ ព្រះជាម្ចាស់ បានធ្វើឲ្យយើងដើរជាមួយគ្នា ដើម្បីឲ្យព្រះសហគមន៍ចាប់ផ្ដើមមានសកម្មភាព មានជីវិត។ ក្រោយមកខ្ញុំនឹងឃើញការសិក្សា ពេលខ្ញុំនៅក្មេងខ្ញុំលេងជាមួយប្អូនស្រីខ្ញុំទី១ ខ្ញុំធ្វើជាគ្រូ ហើយប្អូនស្រីខ្ញុំធ្វើជាសិស្ស និងទី២ ខ្ញុំធ្វើប្រធានធនាគារ និងប្អូនស្រីខ្ញុំមកខ្ចីលុយពីធនាគារខ្ញុំ និងការងារមួយទៀតដែលខ្ញុំចូលចិត្តគឺបោះពុម្ព។ ដោយមើលឃើញការសិក្សាសំខាន់ណាស់ យើងក៏បានចាប់ផ្ដើមជាមួយសាលាមត្តេយ្យរហូតដល់វិទ្យាស្ថាន ការសិក្សាអប់រំសម្រាប់ជីវិតនៃព្រះសហគមន៍ដែរ ជាមួយសាលាអប់រំជំនឿសន្តយ៉ូស្វីន។ អ្វីដែលខ្ញុំចង់ឃើញពីដើមអ្នកក្រីក្រនៅអាហ្វ្រិក ខ្ញុំបានឃើញអ្នកក្រីក្រនៅប្រទេសកម្ពុជា ដើម្បីធ្វើដំណើរជាមួយគ្នា ដើម្បីរួមរស់ជាមួយគ្នា ដើម្បីបង្កើតតម្លៃថ្លៃថ្នូរនៃជីវិតទាំងនៅភូមិសុខសាន្ត ទាំងផ្នែកសិប្បកម្មដែលយើងមានសព្វថ្ងៃ ដើម្បីណែនាំឲ្យមនុស្សទាំងអស់មានជីវិត។

យើងឃើញព្រះយេស៊ូ ណែនាំឲ្យលោកសិលាបានត្រីច្រើនណាស់ ដែលពេញមួយយប់គាត់រកអត់បានសោះ ប៉ុន្តែពេលព្រះយេស៊ូមានព្រះបន្ទូលទៅគេឲ្យទៅកុំខ្លាចអី ចាប់ពីពេលនេះតទៅអ្នកនឹងនេសាទមនុស្សវិញ។ នេះគឺជាតួនាទីដែលបានទទួលពីព្រះជាម្ចាស់ ធ្វើយ៉ាងដើម្បីឲ្យមនុស្សយើងមានតម្លៃថ្លៃថ្នូរ មានកិត្តិយស មានមោទនភាពនៅក្នុងជីវិតផ្ទាល់ ដោយសារមានការងារធ្វើ ដោយសារមានចំណេះដឹង ដោយសារមានសមត្ថភាពផ្ទាល់ខ្លួន។

នៅពេលយើងបានជួបជុំគ្នាពីរថ្ងៃនេះ យើងបានឃើញគ្រួសារដែលមានប្រពន្ធមានកូន គ្រួសារដែលមានសេចក្ដីសុខ គ្រួសារដែលជួនកាលបរាជ័យដែរ ប៉ុន្តែសំខាន់ឲ្យយើងតស៊ូថែមទៀត ដោយសារជីវិតរបស់យើងជាការតស៊ូ។ យើងត្រូវការនឹកឃើញជីវិតរបស់យើងពីដើម ជីវិតរបស់យើងនៅពេលនេះ និងតទៅមុខទៀត។ ដោយសារជីវិតរបស់យើង បីដូចជាផ្ទះមួយដែលយើងសាងសង់ពីមួយថ្ងៃទៅមួយថ្ងៃ យើងបានចាក់គ្រឹះយើងមានឥដ្ឋដែលមានពណ៌ខុសៗគ្នា

យើងមានឥដ្ឋពណ៌ខ្មៅជាភាពងងឹតនៃជីវិតរបស់យើង យើងមានឥដ្ឋពណ៌សដែលជាពន្លឺនៃជីវិតរបស់យើង យើងមានឥដ្ឋពណ៌ក្រហមដែលជាសេចក្តីស្រឡាញ់របស់យើង យើងមានឥដ្ឋពណ៌ត្នោតដែលជាទុក្ខព្រួយនៃជីវិតរបស់យើង យើងមានឥដ្ឋពណ៌ខៀវខ្ចីដែលជាសេចក្តីសង្ឃឹមរបស់យើង។ នេះជាអាគារថ្មីដែលយើងសាងសង់ពីមួយថ្ងៃទៅមួយថ្ងៃ ឥដ្ឋនេះទាំងអស់យើងមិនអាចដកចេញបានទេ បើយើងយកឥដ្ឋមួយចេញជញ្ជាំងវាធ្លាក់ ដូច្នេះវានៅក្នុងជីវិតរបស់យើងទាំងទុក្ខលំបាក ទាំងសេចក្តីសង្ឃឹម ទាំងពន្លឺ ទាំងសេចក្តីស្រឡាញ់ ទាំងសុបិនដែលយើងមានសម្រាប់ជីវិត។ យើងអត់ដឹង ផ្ទះរបស់យើងមានរូបរាងយ៉ាងណា ជីវិតរបស់យើងយើងអត់ដឹងថ្ងៃចុងក្រោយផ្ទះដែលយើងនឹងសាងសង់មានរូបរាងយ៉ាងណា។

ពេលវេលាដែលយើងមាននៅគិរីរម្យរួមជាមួយគ្នា ជាឱកាសមួយដើម្បីនឹកឃើញផ្ទះរបស់យើងមានរូបរាងអ្វីខ្លះ មានសេចក្តីសុខអ្វីខ្លះ មានអំណរសប្បាយអ្វីខ្លះ មានទុក្ខព្រួយអ្វីខ្លះ។ ឲ្យយើងដឹងថា រួមជាមួយគ្នានិងរៀងៗខ្លួនយើងបន្តសាងសង់ផ្ទះនៃជីវិតរបស់យើង ដើម្បីធ្វើយ៉ាងម៉េចឲ្យកូនចៅរបស់យើង មានផ្ទះមួយយ៉ាងស្អាត ដោយមានភាពកក់ក្តៅ ដើម្បីឲ្យគ្រួសាររបស់យើងពោរពេញដោយសេចក្តីសុខសាន្ត។ យើងដឹងហើយព្រះសហគមន៍ ដូចដើមឈើមួយដើមដែលមានមែកច្រើន ដែលបក្សាបក្សីទាំងអស់អាចធ្វើសំបុកបានក្នុងភាពកក់ក្តៅ។ យើងអាចនិយាយថាព្រះសហគមន៍និងជីវិតរបស់យើង ដូចផ្ទះមួយដែលយើងសាងសង់ពីមួយថ្ងៃទៅមួយថ្ងៃ យើងធ្វើយ៉ាងណាឲ្យផ្ទះរបស់យើងស្អាតបំផុត ដោយប្រមូលគ្រប់ទុក្ខលំបាក គ្រប់សេចក្តីសុខនិងគ្រប់អំណរសប្បាយដែលយើងបានទទួល។

ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ សម្រាប់២០ឆ្នាំជាបូជាចារ្យ ២០ឆ្នាំដែលខ្ញុំរស់នៅលើទឹកដីប្រទេសកម្ពុជា សូមព្រះអង្គប្រទានពរដល់បងប្អូនទាំងអស់ ដើម្បីឲ្យយើងរួមគ្នាបន្តកសាងជីវិតរបស់យើង ឲ្យជីវិតរបស់យើងទៅជាជីវិតមួយដែលស្អាតបំផុត ដោយទុកព្រះបន្ទូលរបស់ព្រះយេស៊ូដែលថា "**កុំខ្លាចអី**" ដោយសារយើងមានសេចក្តីក្លាហ៊ានដែលមកពីព្រះជាម្ចាស់ ប៉ុន្តែសេចក្តីក្លាហានមកពីយើងដែរ ដោយសារយើងចេះជួយគ្នាទៅវិញទៅមក យើងចេះលើកទឹកចិត្តគ្នាទៅវិញទៅមកនៅក្នុងកម្លាំង ដើម្បីនឹកឃើញអនាគតកូន អនាគតខ្ញុំណែនាំឲ្យជីវិតរបស់ខ្ញុំ និងផ្ទះនៃជីវិតរបស់ខ្ញុំទៅជាផ្ទះដែលស្អាតបំផុត ដែលពោរពេញដោយសេចក្តីស្រឡាញ់ និងសេចក្តីសង្ឃឹម។ អាម៉ែន៕